**Charting** (ការធ្វើតារាងស្ថិតិធ្មេញ)គឺជារបៀបដែលយើងប្រើ ដើម្បីកត់ត្រារាល់ផ្ទៃទាំងអស់របស់ធ្មេញ ដូចនេះយើងអាចរៀបរាប់ពី ទំហំនៃការខូចខាត ការពុកធ្មេញ រឺ ការប៉ះធ្មេញ ។

វានឹងបង្ហាញអំពី :

- ធ្មេញដែលមានវត្ថុមានក្នុងមាត់
- ធ្មេញដែលបាត់
- ការព្យាបាល ដែលនឹងត្រូវការ
- ការព្យាបាល ដែលបានធ្វើរួច

មានពីររបៀបក្នុងការធ្វើ chart :

- របៀបទី ១ គឺ បែងចែកមាត់ជា ៤ ផ្នែក រឺ 4 quadrants
- របៀបទី ២ គឺ ការដាក់ឈ្មោះអោយធ្មេញនីមួយៗជាលេខ (FDI)

**របៀបទី១:**



ធ្មេញមានចំនួន ១៦គ្រាប់ នៅលើឆ្អឹងថ្គាមនីមួយៗ ។

យើងបែងចែកមាត់ជាបួនភាគស្មើៗគ្នា (quarters រឺ quadrants) ។

១/៤ ផ្នែកខាងលើឆ្វេង

១/៤ ផ្នែកខាងលើស្តាំ

១/៤ ផ្នែកខាងក្រោមស្តាំ

១/៤ ផ្នែកខាងក្រោមឆ្វេង

ប្រសិនបើអ្នកស្រមៃមើល ពេលឆ្អឹងថ្គាមលើក្រោមហាអស់ ហើយពន្លៀតធ្មេញអោយស្ថិតនៅលើបន្ទាត់ត្រង់មួយ នោះយើងនឹងអាចមើលឃើញផ្ទៃទំពាររបស់ធ្មេញ ហើយវានឹងបង្ហាញដូចរូបខាងក្រោមនេះ ។

ផ្នែកខាងលើស្តាំ

ផ្នែកខាងក្រោមស្តាំ



ផ្នែកខាងលើឆ្វេង

ផ្នែកខាងក្រោមឆ្វេង

ឥឡូវនេះយើងដាក់ឈ្មោះធ្មេញជាលេខពី ១ ទៅ ៨ ដោយចាប់ផ្តើមពីផ្នែកកណ្តាល ។ ធ្មេញនេះ គឺជាធ្មេញលេខ១ខាងលើស្តាំ រឺ តាងដោយអក្សរកាត់ UR1 រឺ 1| ។ ធ្មេញនេះគឺធ្មេញលេខ៨ខាងលើស្តាំ រឺតាងដោយអក្សរកាត់ UR8 រឺ 8| ។

**របៀបទី២:**

FDI charting system

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 18 | 17 | 16 | 15 | 14 | 13 | 12 | 11 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 |
| 48 | 47 | 46 | 45 | 44 | 43 | 42 | 41 | 31 | 32 | 33 | 34 | 35 | 36 | 37 | 38 |
| | | | 55 | 54 | 53 | 52 | 51 | 61 | 62 | 63 | 64 | 65 | | | |
| | | | 85 | 84 | 83 | 82 | 81 | 71 | 72 | 73 | 74 | 75 | | | |